AMS

# ក្រុមប្រាសាទភ្នំបារាំង

ក្រុមប្រាសាទភ្នំបារាំង គឺជាបុរាណដ្ឋានដ៏មានសារៈសំខាន់មួយកន្លែងដែលមានទីតាំងស្ថិតនៅឃុំគោល ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដែលព័ទ្ធជុំវិញដោយភូមិចំនួនបួន គឺភូមិកគោ ភូមិកំពង់ផ្លា ភូមិបាក់ស្រី និងភូមិចារ ហើយស្ថិតនៅខាងត្បូងស្ទឹងសែនចម្ងាយប្រមាណ១គ.ម. និងខាងកើតតំបន់ប្រាសាទសំបូរព្រៃគុកប្រមាណ ២០គ.ម.។

ឈ្មោះថា "**បារាំង**" នេះ អ្នកស្រុកបច្ចុប្បន្នយល់ថាកើតចេញមកពីសាច់រឿងព្រេងចំនួនពីរ ដែលរឿងទីមួយដំណាលថា៖ "*កាលពីព្រេងនាយ មានក្របីព្រៃជាច្រើនបានផ្តុំគ្នារកស៊ីក្បែរជើងភ្នំ ហើយមានក្របីបាធំមួយជាអ្នកគ្រប់គ្រងហ្វូងក្របីទាំងនោះ។ ក្របីបានេះមានចិត្តឃោរឃៅខ្លាំងណាស់ ពោលគឺវាមិនអនុញ្ញាតឱ្យកូនក្របីឈ្មោលណាមួយរស់នៅក្នុងហ្វូងនោះឡើយ ហើយបើមានក្របីបានេះនឹងសម្លាប់ចោលទាំងអស់។ រឿងនេះបណ្តាលឱ្យមេក្របីមួយក្បាលបានដឹង និងរកមធ្យោបាយឱ្យកូនរបស់ខ្លួនបានរស់ពេលខ្លួនកំពុងពពោះ ដោយបានគៀសខ្លួនរត់ទៅនៅព្រៃបឹងក្បែរនោះ។ ថ្ងៃក្រោយមកកូនក្របីនោះធំពេញរូបរាងកម្លាំងខ្លាំងក្លា មេវាបានប្រាប់ថា កូនឯងខំស៊ីស្មៅឱ្យបានច្រើន ផឹកទឹកឱ្យបានច្រើន ខំហាត់ជល់ឱ្យបានខ្លាំង ធ្វើយ៉ាងណាត្រូវជល់ដើមក្រសាំងឱ្យជ្រុះផ្លែមក ហើយត្រូវវាត់ផ្លែក្រសាំងដែលធ្លាក់មកទាំងប៉ុន្មានកុំឱ្យធ្លាក់ដល់ដីទាន់។ កូនក្របីនោះខំហ្វឹកហាត់រហូតបានសម្រេចតាមបញ្ជារបស់មេរបស់វា។ មេក្របីបាននាំកូនក្របីទៅជួបក្របីបា។ ពេលនោះក្របីបា និងកូនបានជល់គ្នាខ្ទេចដីខ្ទេចស្មៅ បាក់ព្រៃស្ទើរអស់ ទីបំផុតដោយកូនមានទឹក ស្មៅក្នុងពោះច្រើន មានកម្លាំងច្រើន បានវាត់ក្របីបាធំនោះដួលស្លាប់បាត់ទៅ។ តាំងពីពេលនោះមក ក្របីបាលែងឃើញមកការពារហ្វូងដូចមុនហើយ។ ក្រោយមក អ្នកស្រុកសន្មតថាក្របីបាធំរាងចាលចាញ់បាថ្មី ព្រោះមិនឃើញមកកន្លែងនោះទៀត គេក៏សន្មតឈ្មោះភ្នំនេះថា "**ភ្នំបារាង**" រហូតមក*"។

ចំណែក រឿងព្រេងមួយទៀតដំណាលថា "*កាលដើមឡើយមានមេមុតម្នាក់ (អ្នកចូលរូប) តែងប្រាប់កូនចាបកូនព្រាបដែលរស់នៅខេត្តកំពង់ធំថា៖ ខេត្តកំពង់ធំមានមេទ័ពម្នាក់ឈ្មោះ"**បានរាង**" (អ្នកមានរូបរាងល្អធំសង្ហា)។ គាត់ជាមេទ័ពហ្វឹកហាត់ទ័ពដើម្បីទប់ទល់ និងកំចាត់ទ័ពសៀមដែលឈ្លានពានប្រទេសយើង។ គាត់ប្រមូលទ័ពហ្វឹកហាត់ក្បួនសឹកក្បាច់គុន និងមន្តអាគមនៅលើភ្នំនោះ។ នៅទីបំផុត គាត់បានទប់ទល់កម្ចាត់ទ័ពសៀមបានដោយជោគជ័យ អ្នកស្រុកគ្រប់គ្នា*

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

*ដែលស្រឡាញ់រាប់អានគាត់ ក៏បានសន្មតឈ្មោះគាត់ថា "មេទ័ពបានរាង"។ ក្រោយមកអ្នកស្រុកក៏ហៅភ្នំនោះថា **បានរាង** និងក្រោយមកក្លាយជាភ្នំ **បារាង**"។[១]*

រឿងព្រេងទាំងពីរនេះ ស្តាប់ទៅមិនសមទំនងនឹងការហៅភ្នំនេះថា "**បារៀង**" ឡើយ។ ដ្បិតពាក្យថា "បារៀង" គឺផ្សំមកពីពាក្យចំនួនពីរ គឺពាក្យ "**បា**" និងពាក្យ "**រៀង**"។ ពាក្យ "**បា**" ជាពាក្យមួយដែលខ្មែរហៅវិវឌ្ឍពីពាក្យដើមថា "**ព្រះ**" ដ្បិតក្នុងប្រព័ន្ធភាសារបស់ខ្មែរ ទំនាញពាក្យទៅបែបនេះជារឿងធម្មតាទៅហើយ [ព្រះ > ព្រា > ពា > បា ឬ ប]។ ឧទាហរណ៍ៈ "**ព្រះពុទ្ធ**" ដែលភាសានិយាយរបស់ខ្មែរបែបខ្ទីៗពុំតែ "**ប៉ ប៉ុត**"។ ចំណែក ពាក្យថា "**រៀង**" មានន័យជាកិរិយសព្ទថា *"ដាក់តាមលំដាប់ ធ្វើឱ្យត្រូវលំដាប់ ឱ្យត្រូវរបៀប ឱ្យត្រូវជួរ ឱ្យជាជួរ"* (ឧទាហរណ៍ៈ រៀងលេខ ដាក់រៀងគ្នា ឈររៀងគ្នា ដើមឈើដុះរៀងគ្នា)។[២] ម្ល៉ោះហើយ ការដែលគេហៅភ្នំនេះថា "**បារៀង**" គឺទំនងក្លាយមកពីពាក្យដើមថា "**ព្រះរៀង**" ដែលអាចសំដៅលើតួប៉មប្រាសាទដែលសង់ជាថ្នាក់ៗរៀងគ្នាចាប់ពីចង្កេះភ្នំរហូតដល់កំពូលភ្នំ ព្រោះនៅក្នុងតួប៉មនីមួយៗកាលពីដើមមកសុទ្ធសឹងមានតម្កល់ព្រះអាទិទេព ឬម្យ៉ាងទៀតអាចពីមុនមកគេហៅសំដៅដល់រូបចម្លាក់ដែលមានទេពសង់ខាងតម្កល់នៅក្នុងខ្ទមយាយទេពដែលមានទេពរៀងគ្នា (ជិតគ្នា)។ ឈ្មោះ "**បារៀង**" ទំនងជាឈ្មោះចាស់យូរមកហើយ យ៉ាងហោចណាស់ក៏កើតឡើងនៅពេលដែលប្រាសាទនៅឈរមានរូបរាងដែរ។

ក្រុមប្រាសាទភ្នំបារៀង ធ្លាប់មានអ្នកសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិមកសិក្សាខ្លះៗមកហើយ។ ដំបូងគេ គឺលោក Etienne Aymonier កាលពីឆ្នាំ១៩០០ តែលោកមិនបានសិក្សាអ្វីច្រើននោះឡើយ គ្រាន់តែរៀបរាប់ត្រួសៗនៅក្នុងសៀវភៅរបស់លោកក្នុងទំព័រ ៣៧៤។[៣] ក្នុងឆ្នាំ១៩០២ លោក Lunet De Lajonquière បានសិក្សាបន្ថែម ហើយបានគូរប្លង់ទីតាំងប្រាសាទនៅលើភ្នំ ប៉ុន្តែប្លង់របស់លោកគូរមិនបានសព្វគ្រប់នោះឡើយ ពោល គឺមានតែទីតាំងប្រាសាទមួយកន្លែង និងកាំជណ្តើរបុរាណប៉ុណ្ណោះ។[៤] ក្នុងឆ្នាំ១៩៣៥ លោក Henri Parmentier បានមកសិក្សាបន្ថែមទៀត ហើយជាលទ្ធផលបានច្រើនជាងអ្នកមុនៗ ដ្បិតលោកបានរៀបរាប់អំពីបរិបទទូទៅរបស់ភ្នំ (កម្ពស់៧០ម៉ែត្រ) និងរៀបរាប់អំពីវត្ថុសិល្បៈជាច្រើនដែលមាននៅទីនោះដូចជា រូបព្រះគណេស រូបគោនន្ទិ រូបទេពស្រី ប៉ុន្តែរូបចម្លាក់ទាំងនេះសព្វថ្ងៃបានបាត់ពីទីតាំងដើមអស់ទៅហើយ។[៥] នៅថ្មីៗនេះ

---

[១] *ម៉ែន រី: ២០១៤: ៨*

[២] *ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧: ១០៦៣*

[៣] Aymonier 1900: 374

[៤] Lajonquière 1902: 220-222

[៥] Parmentier 1935: 76-77.

លោក មីសែល ត្រាណោ អ្នកស្រាវជ្រាវជនជាតិខ្មែរ ក៏បានមកសិក្សានៅទីនេះដែរ។ លោកបាន រៀបរាប់ត្រួសៗ និងយោងតាមការបរិយាយរបស់អ្នកស្រាវជ្រាវបារាំង ហើយលោកបានចុះបញ្ជី សិលាចារឹកនៅទីនោះចំនួនមួយផ្ទាំង Ka.101។[៦] មកដល់ឆ្នាំ២០០៨ ក្រសួងវប្បធម៌ និងសាលា បារាំងចុងបូព៌ាបានមកចុះបញ្ជី និងរៀបរាប់អំពីតាំងប្រាសាទចំនួន ៥ កន្លែង ដែលជាទិន្នន័យ លើសការសិក្សាមុនៗ។

ក្រុមប្រាសាទភ្នំបារៀង គេសាងប្រាសាទជាថ្នាក់ៗរៀងគ្នាពីចង្កេះភ្នំនៅផ្នែកខាងកើតរហូត ដល់កំពូលភ្នំ និងបន្តទៅជម្រេភ្នំខាងលិចមួយកន្លែងទៀត ដែលសរុបទាំងអស់មានចំនួន ៥ ទីតាំង ហើយបើគិតជាតួប៉មសរុប ក្រុមប្រាសាទនេះអាចមានតួប៉មសរុប ១១ (សូមមើលប្លង់ខាងក្រោម ដែលយើងតាងពីអក្សរ "ក" ដល់ "ង")។




នៅទីតាំងទីមួយ (ក) ដែលស្ថិតនៅខាងកើតបង្អស់ មានតួប៉មប្រាសាទឥដ្ឋចំនួនមួយ តែសព្វ ថ្ងៃប្រាសាទនេះបានបាក់បែកនៅសល់តែឥដ្ឋរាយប៉ាយប៉ុណ្ណោះ។ ចំណែក ទីតាំងទីពីរ (ខ) ស្ថិត នៅខាងលិចទីតាំងទីមួយ ដែលខ្ពស់ជាងប្រមាណ ៣ម៉ែត្រ ហើយមានតួប៉មប្រាសាទចំនួនមួយ (រាងបួនជ្រុងស្មើ) និងបាក់បែកដូចគ្នា។ ប៉ុន្តែ សព្វថ្ងៃទីតាំងទីពីរនេះ គេសាងសង់ខ្ទមអ្នកតាមួយ

[៦] Tranet 1998: 31-38

នៅពីលើដែលអ្នកស្រុកហៅថា "**យាយទេព**" ហើយខាងក្នុងខ្មមគេតម្កល់ថ្មគោល ចំនួន ៤ ដើម ដែលទំនងមានអាយុកាលចាប់ពីស.វ.ទី១៣-១៦។ ថ្មគោលទាំងនេះ គឺជាប្រភេទថ្មគោលមានឆ្លាក់រូបព្រះពុទ្ធប្រក់នាគមួយចំហៀង និងរូបទេពក្នុងព្រហ្មញ្ញសាសនាមួយចំហៀង (រូបលេខ២១-២)។ កាលពីរវាង២០ឆ្នាំមុន ទីតាំងទីពីរនេះ គេធ្លាប់ប្រទះឃើញចម្លាក់ផ្តែរមានឆ្លាក់សត្វមករនៅខាងចុងដែលជាសិល្បៈរចនាបថសំបូរព្រៃគុក ប៉ុន្តែសព្វថ្ងៃផ្តែរនេះបានបាត់បង់ទៅហើយ។ តាមរយៈសំណល់ឥដ្ឋដែលនៅរាយប៉ាយ ដើងទម្រ និងកស្តុតាងដែលមានផ្តែរឆ្លាក់រូបសត្វមករនៅខាងចុង អាចឱ្យយើងសន្និដ្ឋានបានថា ទីតាំងទីពីរ (ខ) គឺជាប្រាសាទសម័យមុនអង្គរ ក្នុងស.វ.ទី៧។

ដោយឡែក នៅទីតាំងទីបី (គ) វិញ គឺជាទីតាំងសំខាន់មួយនៅក្នុងចំណោមទីតាំងទាំង ៥ កន្លែងនៅលើភ្នំបារៀង។ ទីតាំងនេះមានតួប៉មប្រាសាទសរុបចំនួន ៣ ដែលគេសាងឡើងអំពីឥដ្ឋជាប្ញង់រត់ជួរគ្នាពីជើងទៅត្បូង ហើយសព្វថ្ងៃមានតែតួប៉មកណ្តាលទេដែលនៅសល់រូបរាងច្រើនជាងគេ ពោល គឺនៅសល់ជញ្ជាំងមួយចំហៀង ហ៊ុមព័ទ្ធដោយដើមឈើធំមួយ (រូបលេខ២៣)។ ចំណែកតួប៉មផ្នែកខាងត្បូងនៅសល់ត្រឹមគ្រឹះក្រោម (រូបលេខ២៤) ហើយតួប៉មផ្នែកខាងជើងបានបាក់បែកទាំងស្រុង។ សព្វថ្ងៃនៅខាងមុខតួប៉មកណ្តាល គេបានកសាងសាឡុំថ្មីមួយធ្វើពីបេតុង។ នៅក្នុងសៀវភៅរបស់លោក Lunet De Lajonquière រៀបរាប់ថា៖ "*ទីតាំងនេះមានលក្ខណៈចង្អៀតខ្លាំង ដែលធ្វើឱ្យតួប៉មបីខាងក្រោយរត់មិនត្រង់ជួរគ្នា ពីជើងទៅត្បូងនោះទេ ហើយក្នុងនោះ តួប៉មពីរនៅខាងក្រោយរត់ត្រង់ជួរគ្នាពីជើងទៅត្បូង និងតួប៉មកណ្តាលលយទៅមុខឆ្ពោះទៅទិសខាងកើតខ្លាំង។*[៧] ការដែលលោកបញ្ជាក់ថា "*តួប៉មបីខាងក្រោយរត់មិនត្រង់ជួរគ្នា*" នេះ ទំនងជាលោកគិតថា ទីតាំងនេះមានប្រាសាទចំនួន ៥ ប៉ុន្តែបើពិនិត្យមើលជាក់ស្តែងទីតាំងនេះមានតួប៉មតែ ៣ ទេ។ តួប៉មកណ្តាល សាងអំពីឥដ្ឋ រាងបួនជ្រុងទ្រវែង និងមានតួនាទីសំខាន់ជាងគេដែលសព្វថ្ងៃអ្នកស្រុកហៅតួប៉មនេះថា "**ប្រាសាទដើមច័ន្ទ**"។ នៅតួប៉មកណ្តាល យើងឃើញនៅសល់តែផ្តាំងថ្មមេទ្វារដែលមានបណ្តោយប្រវែង ១៨៣ស.ម. ទទឹង ៨០ស.ម. និងកម្រាស់ ១៤ស.ម.។ រីឯនៅខាងមុខមាននៅសល់ផ្តែរទ្វារមួយ លម្អដោយក្បាច់ស្លឹកឈើកញ្ចុំៗជារាងត្បូងចំនួន ៥ តម្រៀបគ្នានៅក្បាច់បន្ទាត់ធ្នូដែលមានរាងកោងតិចៗ (រូបលេខ២៥)។ ផ្តែរទ្វារនេះមានប្រវែងបណ្តោយ ១៦០ស.ម. ទទឹង ៣០ស.ម. និងកម្រាស់ ២០ស.ម. ដែលមានលក្ខណៈជាសិល្បៈចុងរចនាបថសំបូរព្រៃគុក ដើមរចនាបថព្រៃក្មេងក្នុងស.វ.ទី៧ ហើយបើយើងយកទៅប្រៀបធៀបជាមួយផ្តែរទ្វារនៅតំបន់

[៧] Lajonquière 1902: 220-222

ប្រាសាទសំបូរព្រៃគុកវិញ ពុំមានផ្តែរទ្វារណាមានលក្ខណៈបែបនេះឡើយ។ ក្រៅអំពីនេះ នៅទីតាំងទីបីនេះ មាននៅសល់ទ្រនាប់ជណ្តើរប្រាសាទចំនួន ៣ផ្ទាំង និងបំណែកជើងទម្រចំនួន ៦ផ្ទាំង ដែលសុទ្ធសឹងជាសិល្បៈរចនាបថជាមួយគ្នា។ ទីតាំងប្រាសាទនៅក្រុមទីបីនេះ ជាប្រាសាទឥដ្ឋសាងឡើងនៅចុងរចនាបថសំបូរព្រៃគុក ដើមរចនាបថព្រៃក្មេង ស.វ.ទី៧ ទំនងក្នុងរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ ឬ ព្រះបាទភវវរ្ម័នទី២។

ចំពោះទីតាំងទីបួន (ឃ) វិញ ស្ថិតនៅត្រង់ចំណុចកំពូលភ្នំ ដែលស្ថិតនៅខាងលិចទីតាំងទីបីប្រមាណ ៧០ម៉ែត្រ។ នៅក្រុមនេះ ប្រាសាទទាំងអស់សាងឡើងអំពីឥដ្ឋ មានខឿនក្រាលដោយថ្មកក់ប្រវែងពីលិចទៅកើត៣០ម៉ែត្រ និងពីជើងទៅត្បូង៥៥ម៉ែត្រ ដែលអាចមានតួប៉មប្រាសាទចំនួន ៣ សង់តម្រៀបគ្នារត់អ័ក្សពីជើងទៅត្បូង។ ប៉ុន្តែ ប្រាសាទទាំងអស់បានបាក់រលំអស់ទៅហើយ និងសព្វថ្ងៃអ្នកស្រុកចាក់បេតុងរៀបជាកន្លែងព្រះពុទ្ធរូបធំមួយអង្គ (រូបលេខ៦)។ ឥដ្ឋដែលនៅសល់ច្រើនមានប្រវែងជាមធ្យម បណ្តោយ ២៨-៣០ស.ម. ទទឹង ១៥-១៦ស.ម. និងកម្រាស់ ៦-៨ ស.ម. ដែលមានលក្ខណៈប្រហាក់ប្រហែលឥដ្ឋស.វ.ទី៧ នៅតំបន់ប្រាសាទសំបូរព្រៃគុក។[៨] នៅក្រុមនេះ យើងឃើញមាននៅសល់បំណែកជើងទម្រចំនួន ៣ ដុំ, ស៊ុមទ្វារ, ទ្រនាប់ជណ្តើរ ចំនួន ៣ ផ្ទាំង ដែលជាប្រភេទទ្រនាប់ជណ្តើរសម័យមុនអង្គរ (រចនាបថសំបូរព្រៃគុក ឬព្រៃក្មេង)[៩] និងមាននៅសល់សិលាចារឹកមួយផ្ទាំងដែលទំនងចារឹកនៅស.វ.ទី១០ មានចំនួន ៤៤បន្ទាត់ ស្មើនឹង ២២គាថា។ ជាអកុសល ផ្ទៃកម្ខាងនៃសិលាចារឹកនេះរលុបអស់មើលលែងយល់។ ចារឹកនេះ ចារជាភាសាសំស្ក្រឹត ហើយពុំធ្លាប់មានអ្នកស្រាវជ្រាវណាបានបកប្រែនិងចុះផ្សាយនៅឡើយទេ (រូបលេខ៧)។ យើងមិនដឹងអត្ថន័យនៃសិលាចារឹកនេះមានខ្លឹមសារនិងអត្ថន័យយ៉ាងណាឱ្យប្រាកដនោះឡើយ។ តាមការរៀបរាប់ខាងលើនេះបង្ហាញថា ទីតាំងទីបួនដែលស្ថិតនៅចំកំពូលភ្នំនេះទំនងមានប្រាសាទធ្វើអំពីឥដ្ឋចំនួន ៣ ដែលសាងនៅស.វ.ទី៧ តែអាចមានជួសជុលនិងសាងបន្ថែមខ្លះក្នុងស.វ.ទី១០ រវាងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ ដល់ព្រះបាទជ័យវរ្ម័នទី៥។ ចំពោះ ទីតាំងប្រាសាទទីប្រាំ (ង) វិញ ស្ថិតនៅខាងលិចទីតាំងប្រាសាទទីបួន ហើយជាតួប៉មប្រាសាទដែលសាងអំពីឥដ្ឋ មានរាងបួនជ្រុងស្មើ តែសព្វថ្ងៃបានបាក់បែកអស់នៅសល់តែបំណែកឥដ្ឋរាយប៉ាយតែប៉ុណ្ណោះ។

---

[៨] សាន វីណា ២០១៣

[៩] ជន ច័ន្ទណារ័ត្ន ២០១៨: ១៥-២១

ក្រៅពីក្រុមប្រាសាទទាំងប្រាំដែលបានរៀបរាប់ខាងលើ នៅទីនេះធ្លាប់មានវត្ថុសិល្បៈមួយចំនួនដូចជា លិង្គឥស្សរមួយ បំណែករូបចម្លាក់គោនន្ទិ បដិមាព្រះគណេស រូបដងខ្លួនទេពប្រុស រូបបដិមាភេទស្រីមានព្រះហស្តប្រាំមួយ តែបាក់កែងដៃមួយនិងផ្នួងសក់ចងទៅលើ។[៩០] ប៉ុន្តែ វត្ថុទាំងនេះពុំមាននៅសល់ទៀតទេ។ នៅលើភ្នំបាវៀង ក៏មានសេសសល់រចនាសម្ព័ន្ធជណ្តើរបុរាណឡើងភ្នំផងដែរ តែសព្វថ្ងៃគេបានប្រើប្រាស់បេតុងបិតពីលើជណ្តើរចាស់។ នៅច្រកចូលខាងជើង មានស្រះទឹកធំពីរ។ ជាងនេះទៅទៀត នៅទីតាំងប្រាសាទទីបី (គ) យើងឃើញមានក្រឡភាជន៍ជាច្រើនដែលគេដាក់ផ្អឹងនៅខាងក្នុងកប់តាមជម្រាលភ្នំ ដែលសុទ្ធសឹងជាភាជន៍នាំចូលពីប្រទេសចិន និងជប៉ុននៅស.វ.ទី១៦-១៨។ នៅលើក្រឡភាជន៍មានចារឹកអក្សរចិនបុរាណ និងជប៉ុន ដែលមានន័យថា “**អាយុ - សូមសំណាងល្អ**” (រូបលេខ៨) ការកប់ផ្អឹងបែបនេះ ដោយហេតុថា គេជឿថា ភ្នំបាវៀងគឺជាទីស្ថានសក្ការបូជាដ៏ស័ក្តិសិទ្ធិតាំងពីសម័យមុនអង្គរ បន្តរហូតដល់សម័យអង្គរ និងសម័យកណ្តាល។

ជារួមមក ភ្នំបាវៀង គឺជាទីតាំងទីសក្ការបូជាផ្នែកព្រហ្មញ្ញសាសនាតាំងពីស.វ.ទី៧ ដែលមានប្រាសាទធ្វើអំពីឥដ្ឋជាតឹកតាងស្រាប់ និងមានសាងបន្ថែមនៅស.វ.ទី១០ ហើយបន្តប្រណិប័តន៍ជំនឿរហូតមកទល់សព្វថ្ងៃ។ លក្ខណៈពិសេសមួយនៃបុរាណដ្ឋានភ្នំបាវៀងដែលយើងគួរលើកយកមកពិចារណានោះគឺ ក្រុមប្រាសាទភ្នំបាវៀង គឺជាទីតាំងតែមួយគត់នៅកម្ពុជាដែលមានប្រាសាទធ្វើអំពីឥដ្ឋនៅស.វ.ទី៧ សាងជាថ្នាក់ៗរៀងគ្នាតាំងពីចង្កេះភ្នំដល់លើកំពូលភ្នំ ចំនួន ៩ ទីតាំង ដែលសរុបជាតួប៉មមានរហូតដល់ទៅ ១១។ ការសាងសង់ប្រាសាទរបៀបនេះ ជាគំនិតមានលក្ខណៈមូលដ្ឋានប្រហាក់ប្រហែលនឹងការសាងប្រាសាទពីរ៉ាមីតនៅចុងសម័យមុនអង្គរ និងអង្គរដែរ។

KHMER CIVILIZATION

[90] Lajonquière 1902: 222.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ១-២ៈ ថ្មគោលមានចម្លាក់រូបទេពព្រហ្មញ្ញសាសនាម្ខាង ទេពព្រះពុទ្ធសាសនាម្ខាង



រូបលេខ៣ៈ ប្រាសាទនៅសល់រូបរាងនៅទីតាំងទីបី (តួប៉មកណ្ដាល)

អត្ថបទដោយៈ ម៉ង់ រ៉ាលី



រូបលេខ២៤៖ ប្រាសាទនៅសល់រូបរាងនៅទីតាំងទីបី (តួប៉មផ្នែកខាងត្បូង)



រូបលេខ២៥៖ ផ្តែរទ្វារដើមរចនាបថព្រៃក្មេង ស.វ.ទី៧ រកឃើញនៅទីតាំងទីបី

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ២៦-៣៧៖ ទីតាំងទីបួន និងសិលាចារឹកមួយផ្ទាំងចារឹកនៅស.វ.ទី១០



រូបលេខ២៨៖ កុលាលភាជន៍ដាក់ឆ្អឹង
រកឃើញនៅតាមជម្រាលភ្នំ នៃទីតាំងទីបី

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

## ឯកសារយោង

**ជន ច័ន្ទណារ័ត្ន**

២០១៨, *ការវិវត្តទ្រនាប់ជណ្តើរនៅក្នុងសិល្បៈខ្មែរ*, ភ្នំពេញ

**ម៉ែន វីរៈ**

២០១៤, *ក្រុមប្រាសាទភ្នំបាវៀង*, ភ្នំពេញ

**សាន វីណា**

២០១៣, *បច្ចេកទេសតម្រៀបឥដ្ឋនៅសំបូរព្រៃគុក*, ភ្នំពេញ

**ពុទ្ធសាសនបណ្ឌិត្យ**

១៩៦៧, *វចនានុក្រមខ្មែរ*, ភ្នំពេញ

**Aymonier, Etienne**

1900, *"Le Cambodge"*, *Tome I, Le royume actuel*, Paris.

**Lunet De Lajonquière**

1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris

**Michael Tranet**

1998, *Sambor Prei Kuk, Monuments d'Isanavarman (615-628) et ses environs, 3Vol, Phnom Penh*

**Parmentier, Henri**

1935, Complément à l'inventaire descriptive des monuments du Cambodge, *BEFEO*, 35, Paris


អត្ថបទដោយ៖ ម៉ង់ រ៉ាលី